អង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា

# របាយការណ៍ស្រាវជ្រាវសង្ខេប បរិយាប័ន្នសង្គមនៅក្នុងការអភិវឌ្ឍមូលដ្ឋាន និងឱកាសប្រើប្រាស់បណ្តាញសង្គមឆ្ពោះទៅទំនើបកម្មនៃកម្មវិធីវិនិយោគឃុំ ឆ្នាំ ២០២៥

អនុវត្តដោយ

ANSA Cambodia
Connecting Citizens to improve Governance

ឧបត្ថម្ភដោយ

Australian Aid

PONLOK CHOMNES

The Asia Foundation

# អំណះអំណាង

ការស្រាវជ្រាវនេះទទួលបានការឧបត្ថម្ភគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ របស់អង្គការមូលនិធិអាស៊ី៖ ទិន្នន័យ និងការពិភាក្សាសម្រាប់ការអភិវឌ្ឍនៅកម្ពុជា ទស្សនៈដែល លើកឡើងនៅក្នុងការស្រាវជ្រាវនេះគឺជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ពោលគឺមិនបានឆ្លុះបញ្ចាំងអំពី ទស្សនៈ និងការយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ីឡើយ។

# មាតិកា

- សេចក្ដីផ្ដើម
- និន្នាការចម្បងៗនៃសេដ្ឋកិច្ចសង្គម
- និន្នាការចម្បងៗផ្នែកគោលនយោបាយ
- របកគំហើញ និងទិដ្ឋភាពស៊ីជម្រៅបែបគុណភាព
- សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

# សេចក្ដីផ្ដើម

សារៈតារ គោលបំណង
និងវិធីសាស្ត្រនៃការស្រាវជ្រាវ

# សាវតារ និងស្ថានភាពទូទៅ

- រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឲ្យមាន និងអនុវត្តគោលនយោបាយសំខាន់ៗ ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការនៃក្រុមដែលងាយរងគ្រោះ
  - ក្នុងចំណោមប្រជាពលរដ្ឋ៖ ជាយុវជន ស្ត្រី ជនពិការ និង ជនជាតិដើមភាគតិច
  - គោលនយោបាយចម្បង៖ ការគាំពារសង្គម កម្មវិធីជួយជនក្រីក្រ និង អភិបាលកិច្ចមូលដ្ឋាន
- មានតម្រូវការយកចិត្តទុកដាក់បន្ថែមចំពោះក្រុមដែលងាយរងគ្រោះជាពិសេស នៅក្រោយបរិបទកូវីដ-១៩
- បរិយាប័ន្នសង្គម គឺសំដៅដល់ ការធានាការចូលរួមដោយក្រុមដែលងាយរងគ្រោះ និងធ្វើឲ្យសំឡេងរបស់ពួកគេត្រូវបានលឺជាសាធារណៈ
- នៅក្នុងកំណែទម្រង់វិមជ្ឈការ ការចូលរួមរបស់ក្រុមដែលងាយរងគ្រោះ គឺជាគោលបំណងសំខាន់មួយរបស់គោលនយោបាយ
  - លើកកម្ពស់ការចូលរួមក្នុងដំណើរការ កម្មវិធីវិនិយោគឃុំ
  - ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ
- និន្នាការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ចសង្គមឆាប់រហ័ស ទាមទារឲ្យមានការវាយតម្លៃ និងការសម្រួលទៅលើគោលនយោបាយដែលមានស្រាប់ និងការឆ្លើយតប

# គោលបំណង និងវិធីសាស្ត្រ

- គោលបំណងនៃការស្រាវជ្រាវ
  - កំណត់នូវនិន្នាការផ្នែកសេដ្ឋកិច្ចសង្គម និងគោលនយោបាយចម្បងៗជុំវិញបរិយាប័ន្នសង្គមនៅថ្នាក់មូលដ្ឋាន
  - វាយតម្លៃទៅលើការអនុវត្តជាក់ស្តែងនៃបរិយាប័ន្នសង្គមនៅក្នុងដំណើរការកសាងផែនការនៅមូលដ្ឋានបច្ចុប្បន្ន
  - ស្នើឲ្យមានការពិចារណាដាក់បញ្ចូលនូវការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមដើម្បីលើកកម្ពស់បរិយាប័ន្នសង្គម
- វិធីសាស្ត្រ
  - ការពិនិត្យមើលទៅលើគោលនយោបាយ និងឯកសារស្រាវជ្រាវផ្សេងៗ
  - ពិនិត្យមើលទៅលើការប្រើប្រាស់មធ្យោបាយឌីជីថលដែលបម្រើដល់សេវាសាធារណៈ និងការចូលរួមរបស់ពលរដ្ឋនៅមូលដ្ឋាន
  - ការប្រមូលទិន្នន័យនៅតាមតំបន់គោលដៅនៃខេត្តចំនួន៣ ដែលមានសំណាកចំនួន ៣៣៥ នាក់
  - ការសម្ភាសបែបគុណភាព និងការសង្កេតនៅតំបន់គោលដៅ



# សារសំខាន់ៗ

- ការប្រែប្រួលប្រជាសាស្ត្រ ចំណាកស្រុក បញ្ហាកូវីដ-១៩ កម្រិតខ្ពស់នៃការមកដល់នៃអ៊ិនធឺណិត និងបណ្ដាញសង្គមដ៏សំបូរបែប គឺជាកត្តាសំខាន់សម្រាប់មុខព្រួញនៃនិន្នាការសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា
- រដ្ឋាភិបាលបានយកចិត្តទុកដាក់បន្ថែមទៀតទៅលើក្រុមដែលងាយរងគ្រោះជាពិសេសក្នុងបរិបទនៃការរីករាលដាលកូវីដ-១៩ និងផលប៉ះពាល់របស់វា
- ការចូលរួមនៅមូលដ្ឋានរបស់ក្រុមដែលងាយរងគ្រោះត្រូវបានផ្ដល់ឲ្យនៅក្នុងដំណើការបច្ចុប្បន្នប៉ុន្តែការអនុវត្តជាក់ស្ដែងមានភាពខុសគ្នាពីកន្លែងមួយទៅមួយ
- យុវជន និងបច្ចេកវិទ្យាព័ត៌មានគឺជាដំណោះស្រាយស្នូលសម្រាប់ធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចមូលដ្ឋាន ប៉ុន្តែការគិតគូរបែបនវានុវត្តន៍ និងការរៀនសូត្រផងធ្វើផង គឺជាមានភាពចាំបាច់សម្រាប់បំពេញឲ្យសក្ដានុពលនេះ
- អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមូលដ្ឋាន ជាដៃគូមិនអាចខ្វះបានសម្រាប់គំនិតផ្ដួចផ្ដើមនៅតាមឃុំសង្កាត់ និងជំរុញឲ្យមានដំណោះស្រាយជាវិជ្ជមាន

# និន្នាការចម្បងៗផ្នែកសេដ្ឋកិច្ចសង្គម

## ទិន្នន័យប្រជាសាស្ត្រចុងក្រោយ ចំណាកស្រុក និងការប្រើប្រាស់អ៊ិនធឺណិតនៅកម្ពុជា

# ទិន្នន័យប្រជាសាស្ត្រចុងក្រោយនៅកម្ពុជា

- ក្រុមពលរដ្ឋសំខាន់ៗទៅតាមជំរឿនប្រជាសាស្ត្រ ២០១៩
  - ស្ត្រី៖ ៥១%
  - យុវជន (១៨-៣៥ឆ្នាំ)៖ ៣១%
  - មនុស្សចាស់ (>៦០ឆ្នាំ)៖ ១០%
  - ជនជាតិដើមភាគតិច៖ ៤%
  - ជនពិការ៖ ៥%
- ចំណាកស្រុក ជាចលករសេដ្ឋកិច្ច សង្គមនៅទូទាំងប្រទេស

ភាគរយនៃគ្រួសារដែលមានសមាជិកគ្រួសារចំណាកស្រុក (ឆ្នាំ២០១៨) ប្រភព WFP (២០១៩)



# ភាពងាយរងគ្រោះនានាដោយសារកូវីដ-១៩

- កូវីដ-១៩ អាចនាំឲ្យមានភាពក្រីក្រទ្វេដងរហូតដល់ ១៧.៦% ដោយចំនួនមនុស្សប្រមាណ ១.៣៤ លាននាក់អាចវិលទៅរកភាពក្រីក្រវិញ (UNDP, 2020)
- កូវីដ-១៩ អាចនាំឲ្យថយចុះ៣០%នូវប្រាក់ចំណូលជាមធ្យម (ពី ២៣៧$ក្នុងខែមករា ឆ្នាំ២០២០ មកត្រឹម១៦៧$)ដោយសារការបិទរោងចក្របណ្តោះអាសន្ន រួមទាំងការកាត់បន្ថយម៉ោងធ្វើការ និងបាត់បង់ប្រាក់ម៉ោងបន្ថែម (CPS et al, 2020)
- យ៉ាងហោចណាស់ ៦០%នៃអាជីវករខ្នាតតូចអាចនឹងថយចុះនូវប្រាក់ចំណូល។ អាជីវកម្មផ្នែកបដិសណ្ឋារកិច្ច ឬ ទេសចរណ៍ រងនូវផលប៉ះពាល់ខ្លាំងជាងគេដោយសារកូវីដ-១៩ (UNIDO, 2020; CPS 2020)
- ពលករចំណាកស្រុកប្រមាណ១០០០០០នាក់បានវិលត្រឡប់ពីប្រទេសថៃមកស្រុកកំណើតវិញដោយសារវិបត្តិកូវីដ-១៩ (ILO, 2020).
- បំណុលប្រចាំគ្រួសារ កើនឡើង ហើយពួកគេស្វែងរកកម្ចីបន្ថែមទៀត។តាមរយៈការស្ទង់មតិមួយ បំណុលកើនឡើងពី៥៩%នៅខែមករា ទៅដល់៦១.៧%នៅខែមេសា ឆ្នាំ២០២០ (CPS et al, 2020)
- អត្រានៃភាពអត់ការងារធ្វើអាចកើនដល់៤.៨% (UNDP, 2020).
  - តើអ្នកធ្វើចំណាកស្រុកនៅទីក្រុងអាចត្រឡប់ទៅស្រុកវិញដែរឬទេដោយសារការបាត់បង់ការងារ?

# ការប្រើប្រាស់អ៉ីនធឺណិត និងបណ្ដាញទំនាក់ទំនងសង្គមនៅកម្ពុជា

ផ្អែកលើរបាយការណ៍ #Digital2020 report for Cambodia

- អ្នកប្រើប្រាស់អិនធឺណិត (ត្រឹមខែមករា ២០២០)
  - អ្នកប្រើប្រាស់អ៉ីនធឺណិត៖ ៩. ៧លាននាក់
  - កើនជាង ១.៣ លាននាក់ ប្រៀបនឹងឆ្នាំ ២០១៩
  - ការទទួលបានអិនធឺណិត៖ ៥៨%
- អ្នកភ្ជាប់អិនធឺណិតតាមទូរស័ព្ទចល័ត
  - ២១,២៤ លាន
  - កើនជាង៧៦៥.០០០ (៣.៧%)ពីឆ្នាំ២០១៩
  - ស្មើនឹង ១២៨% នៃចំនួនពលរដ្ឋសរុប
- អ្នកប្រើប្រាស់បណ្ដាញសង្គមនៅកម្ពុជា
  - ៩.៧០ លាននាក់
  - កើន ១. ៤ លាន (១៧%) ពីឆ្នាំ ២០១៩
  - អត្រានៃការប្រើប្រាស់បណ្ដាញសង្គម៖ ៥៨%
- ត្រឹមឆ្នាំ២០១៨ ចំនួនអ្នកបានភ្ជាប់អិនធឺណិតធៀបនឹងចំនួនអ្នកបោះឆ្នោត
  - តំបន់មានភាគរយខ្ពស់៖ ព្រះសីហនុ ៥៥៥% ភ្នំពេញ ៤០០%
  - តំបន់មានភាគរយទាប៖ ឧត្តរមានជ័យ ព្រះវិហារ រតនគិរី មណ្ឌលគិរី ក្នុងចំនួន ៥០%
  - ទោះជាយ៉ាងណា មានការកើនឡើងយ៉ាងគំហុក នៅខេត្តជាច់ស្រយាល

# និន្នាការផ្នែកគោលនយោបាយសំខាន់ៗ

គោលនយោបាយចម្បងៗ ស្តីពីការធ្វើផែនការនៅមូលដ្ឋាន និងការដាក់បញ្ចូលនវានុវត្តន៍ផ្នែកឌីជីថល

# ទិដ្ឋភាពរួមនៃដំណើរការកសាងផែនការនៅមូលដ្ឋាន និងគោលនយោបាយចម្បងៗ




- នៅក្នុងគោលនយោបាយ
  - ផ្តោតលើតម្រូវការ/សំឡេងរបស់ពលរដ្ឋទាំងអស់ ជាពិសេសក្រុមដែលងាយរងគ្រោះ
  - កម្មវិធីជាតិ ១០ឆ្នាំលើកទី២ សង្កត់ធ្ងន់ទៅលើបរិយាប័ន្នសង្គម
  - ចាប់ផ្តើមផ្តោតយកចិត្តទុកដាក់លើអភិបាលកិច្ចអេឡិចត្រូនិក
  - គណៈកម្មការស្ត្រី និងកុមាររបស់ឃុំ ដើរតួនាទីសំខាន់នៅពេលនិយាយដល់ក្រុមងាយរងគ្រោះ

# គោលនយោបាយផ្សេងទៀត
# ឬគំនិតផ្តួចផ្តើមដែលផ្តោតលើបរិយាប័ន្នសង្គម

- កម្មវិធី និងគោលនយោបាយគាំពារសង្គម
  - ជំនួយសង្គម និងការផ្តល់សាច់ប្រាក់ដល់ក្រុមគោលដៅជាក់លាក់
  - វិភាគទានសាច់ប្រាក់ធានារ៉ាប់រងសុខភាពជូនកម្មករនិយោជិត
- ការពង្រីកកម្មវិធីជួយអ្នកក្រ
- ការផ្តល់សាច់ប្រាក់ សម្រាប់ក្រុមរងគ្រោះដោយសារកូវីដ-១៩
- ការពង្រីកនូវការផ្តល់វិភាគទានសុខភាពសម្រាប់កម្មករក្នុងប្រព័ន្ធ
  - នៅតែមានឧបសគ្គសម្រាប់ក្រុមសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- គោលនយោបាយភូមិឃុំមានសុវត្ថិភាព ឆ្នាំ២០២១ នៅតែនិយាយអំពីក្រុមដែលងាយរងគ្រោះ

- នៅតែមានការផ្តោតទៅលើសេវាសង្គម
- ផែនការដើម្បីបន្ថែមថវិកាសម្រាប់សេវាសង្គម
- កំណែទម្រង់ ដើម្បីលើកកម្ពស់ដំណើការថវិកានៅថ្នាក់ក្រោមជាតិ
- ក្របខណ្ឌគណនេយ្យភាពសង្គមដំណាក់កាលទី២

# ការលេចចេញនូវគំនិតផ្តួចផ្តើមអភិបាលកិច្ចអេឡិចត្រូនិកនៅថ្នាក់មូលដ្ឋាន

- កម្មវិធីជាតិ១០ឆ្នាំដំណាក់កាលទី២ ស្តីពីវិមជ្ឈការនិងវិសហមជ្ឈការផ្តោតទៅលើតម្រូវការបន្ទាន់សម្រាប់អភិបាលកិច្ចអេឡិចត្រូនិក
  - សេវាបែបអេឡិចត្រូនិក
  - រដ្ឋបាលអេឡិកត្រូវនិក
  - ការចូលរួម ឬផ្តល់មតិយោបល់អេឡិចត្រូនិក
- គំរូដែលមានស្រាប់នៃសេវាតាមអេឡិចត្រូនិក
  - ការផ្តល់សេវារដ្ឋបាលតាមរយៈការិយាល័យច្រកចេញចូលតែមួយ
  - ការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ទម្លាក់ថវិកាទៅថ្នាក់មូលដ្ឋាន
  - ការប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មាន និងគាំទ្រអតិថិជន
- គំរូដែលមានស្រាប់ចំពោះនៃរដ្ឋបាលអេឡិកត្រូនិក
  - ការប្រើប្រាស់ជាទូទៅនៃបណ្តាញសង្គមជាពិសេស តេឡេក្រាមក្នុងចំណោមមន្ត្រីថ្នាក់ក្រោមជាតិ
  - ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់ការផ្តល់សេវា
- គំរូដែលមានស្រាប់ នៃការផ្តល់មតិយោបល់បែបអេឡិកត្រូនិក
  - ការសាងល្បងកម្មវិធីមួយចំនួនដូចជា I-SAF
- ឧបសគ្គចម្បង
  - ការផ្តួចផ្តើមកើតមានតែមិនទាន់ខ្លាំងក្លា
  - មិនទាន់មានលក្ខណៈជាស្ថាប័ន និងអនុវត្តដោយផ្នែក
  - ការផ្លាស់ប្តូរផ្នត់គំនិតនៅតែជាឧបសគ្គ

# របកគំហើញពីការប្រមូលទិន្នន័យ

របកគំហើញពីការស្ទង់មតិ
និងការយល់ឃើញបែបគុណភាព

# សំណាក

| ក្រុមមនុស្សទៅតាមភូមិសាស្ត្រ | ភាគរយនៃអ្នកផ្តល់ចម្លើយ៣៣៥ នាក់ |
|---|---|
| ស្ត្រី | ៦៥% |
| យុវជន(១៨-៣៥ ឆ្នាំ) | ៣៤% |
| មនុស្សចាស់ អាយុច្រើនជាង៦០ឆ្នាំ | ១៣% |
| ជនពិការ | ៣% |
| ពីសមាជិកគ្រួសារដែលមានអ្នកចំណាកស្រុកយ៉ាងហោចម្នាក់ | ៣៤% |
| ប្រជាជននៅខេត្តរតនគិរី ភាគច្រើន ជាជនជាតិដើមភាគតិច | ៣៤% |

# ស្ថានភាពចំណាកស្រុក និងទិដ្ឋភាពទាក់ទងនឹងកូវីដ-១៩

- ភាគរយខ្ពស់នៃចំណាកស្រុកនៅខេត្តតាកែវ និងសៀមរាបប៉ុន្តែស្ទើរតែគ្មាននៅខេត្តរតនគិរី
- ជនចំណាកស្រុកភាគច្រើនជាយុវជន
- ហេតុផលចម្បងគឺ រកការងារធ្វើ
- ការព្រួយបារម្ភក្នុងការរកលុយមកសងបំណុលធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ
- ជាមួយនឹងបញ្ហាកូវីដ-១៩ មិនច្បាស់ថាសមាជិកដែលចំណាកស្រុកនឹងវិលមកផ្ទះវិញ
- ការបារម្ភជាទូទៅ និងភាពមិនច្បាស់លាស់ជុំវិញបញ្ហាកូវីដ-១៩



# កម្រិតនៃការចូលរួមនៅតាមខេត្ត (១)




- ជារូបភាពរួម
  - ៦០%និយាយថា ពួកគេត្រូវបានអញ្ជើញទៅចូលរួមក្នុងកម្មវិធីវិនិយោគឃុំ
  - ៤៥% ថា ពួកគេពិតជាបានចូលរួមប្រជុំ
  - ៦៥% ថាពួកគេបានឮអំពីកម្មវិធីវិនិយោគឃុំ
- ភាពខុសគ្នាទៅតាមភូមិសាស្រ្ត
  - នៅខេត្តតាកែវមានភាគរយទាបជាងគេដោយពលរដ្ឋនិយាយថា បានចូលរួមចំនួន២៥%
  - នៅសៀមរាប មានអត្រាភាគរយខ្ពស់ជាងគេរហូតដល់ជិត ៦០%

# កម្រិតនៃការចូលរួម តាមខេត្ត ( ២ )




- ជារូបភាពរួម
  - ៤០%នៃអ្នកឆ្លើយសំណួរថាពេញចិត្តនឹងដំណើការកម្មវិធីវិនិយោគឃុំ
  - ប្រមាណ៤០% ឲ្យដឹងថា បានផ្តល់ធាតុចូលពេលបានចូលរួមប្រជុំកម្មវិធីវិនិយោគឃុំ
  - ជិត៧០% និយាយថា ពួកគេបានចូលរួមប្រជុំកម្មវិធីវិនិយោគឃុំក្រោយការអញ្ជើញ
- ភាពខុសគ្នាទៅតាមតំបន់
  - ពលរដ្ឋតិចណាស់និយាយថាពួកគេពេញចិត្តនឹងដំណើរការកម្មវិធីវិនិយោគឃុំ (តែ២០%)នៅខេត្តរតនគិរី ខណៈនៅតាកែវមានប្រមាណ៣០%
  - នៅខេត្តសៀមរាបមានអត្រានៃការពេញចិត្តក្នុងកម្រិតខ្ពស់ ប្រមាណជា៧០%

# កម្រិតនៃការចូលរួម តាមប្រភេទអ្នកឆ្លើយសំណួរ (១)




- ពលរដ្ឋចង់ឲ្យមានការអញ្ជើញចូលរួម ក្នុងកម្មវិធីវិនិយោគឃុំ
- ការអញ្ជើញត្រូវបានធ្វើឡើងដោយចុះជួបផ្ទាល់
- មេភូមិ និងអាជ្ញាធរនៅតែមានតួនាទីសំខាន់ក្នុងការអញ្ជើញពលរដ្ឋដោយផ្ទាល់
- ការអញ្ជើញដោយផ្ទាល់រួមចំណែកដល់ការរើសអើងនយោបាយ (ប្រជាជនដែលត្រូវបានគេដឹងថាមាននិន្នាការផ្ទុយមិនត្រូវបានគេអញ្ជើញ)
- យុវជនជាទូទៅមិនត្រូវបានអញ្ជើញជាទៀងទាត់ និងត្រូវបានគេឃើញថាមានពិបាកក្នុងការអញ្ជើញមកប្រជុំ និងពិបាកណែនាំ

# កម្រិតនៃការចូលរួម តាមប្រភេទអ្នកឆ្លើយសំណួរ (២)




- ជាទូទៅ ដោយមិនគិតពីលក្ខណៈសម្បត្តិជាក់លាក់
  - ជារួម ភាគរយខ្ពស់នៃពលរដ្ឋនិយាយថាបានចូលរួមបន្ទាប់ពីពួកគេត្រូវបានអញ្ជើញ
  - ទោះជាយ៉ាងណា មានចំនួនតិចណាស់ដែលថា ពួកគេបានផ្តល់ធាតុចូលនៅក្នុងពេលប្រជុំ
  - ប្រមាណជាពាក់កណ្តាលបាននិយាយថា ពួកគេពេញចិត្តនឹងដំណើការកម្មវិធីវិនិយោគឃុំ
  - ទាំងអស់គ្នាសុទ្ធតែអះអាងថាកូវីឌ-១៩ធ្វើអោយការប្រជុំជួបឧបសគ្គ
- យុវជនជាច្រើនបានធ្វើចំណាកស្រុកហើយមិនបានចូលរួមក្នុងដំណើការកម្មវិធីវិនិយោគឃុំ

# របកគំហើញពីការស្រាវជ្រាវបែបគុណភាព

- មេឃុំ/មន្ត្រីនៅសាលាឃុំជាច្រើនសុទ្ធតែអះអាងថា បានប្រើប្រាស់ តេឡេក្រាមក្នុងការទាក់ទងគ្នាពីជាមួយថ្នាក់ក្រោម និងថ្នាក់លើ
- សម្រាប់ការងារប្រចាំថ្ងៃ ទៅលើការងារថវិកា និងធ្វើផែនការជាដើមគឺនៅតែប្រើក្រដាស
- មានយុវជនជាច្រើនមានការពេញចិត្តធ្វើការជាមន្ត្រីកិច្ចសន្យា ជាជំនួយការឃុំ។ យុវជនត្រូវបានអង្កេតឃើញថាអាចជួយកិច្ចការបានច្រើន ជាពិសេសការងារផ្នែករដ្ឋបាល និងទាក់ទងនឹងការប្រើកុំព្យូទ័រ
- បរិបទកូវីដ-១៩ តម្រូវឲ្យមនុស្សយល់ដឹងពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបណ្ដាញទំនាក់ទំនងសង្គមដើម្បីទាក់ទងគ្នា
    - ទោះជាយ៉ាងណាវានៅតែជាឧបសគ្គចំពោះអ្នកមិនទាន់ដឹងពីបច្ចេកវិទ្យាថ្មីៗ (មនុស្សចាស់ និងអ្នកដែលគ្មានអ៊ិនធឺនិតប្រើ)

# អនុសាសន៍

# អនុសាសន៍ចម្បងៗ (១)

- ផលប៉ះពាល់នៃកូវីដ-១៩ គួរតែដាក់បញ្ចូលនៅពេលកំណត់ក្រុមដែលងាយរងគ្រោះនៅកម្រិតឃុំ។ វាគួរតែស្របតាមដំណើការដែលបានប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណអ្នកក្រីក្រ
- ក្រុមដែលគេត្រូវយកចិត្តទុកដាក់បន្ថែម
  - គ្រួសារដែលមានសមាជិកធ្វើចំណាកស្រុកហើយពឹងអាស្រ័យលើប្រាក់ដែលផ្ញើមក
  - កម្មករដែលពឹងតែប្រាក់ខែមួយមុខជាពិសេស ក្រុមដែលធ្វើការក្នុងសហគ្រាសទេសចរណ៍ និងកាត់ដេរ
  - មនុស្សចាស់ដែលមានបញ្ហាសុខភាព
- កម្មវិធីវិនិយោគឃុំបច្ចុប្បន្ន មានភាពគ្រប់គ្រាន់ក្នុងការលើកទឹកចិត្តឲ្យពលរដ្ឋចូលរួម ដែលរួមមានក្រុមដែលងាយរងគ្រោះ។ ដើម្បីធ្វើអោយប្រសើរជាបន្តទៀត ការអនុវត្តគួរតែអាចប្រែប្រួលទៅតាមតំបន់
  - ត្រូវមានវិធីសាស្ត្របែបច្នៃប្រឌិត ដើម្បីបង្កើនការយល់ដឹងអំពីដំណើការកម្មវិធីវិនិយោគនៅក្នុងចំណោមមន្ត្រីឃុំសង្កាត់។វិធីសាស្ត្រប្រើបច្ចុប្បន្ន (ការផ្តល់វគ្គបណ្តុះបណ្តាល) នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ
  - ការផ្សព្វផ្សាយតាមអនឡាញបែបសាមញ្ញៗ ដូចជាការជូនដំណឹងតាម (តេឡេក្រាម ហ្វេសប៊ុក) គួរតែមានក្នុងកម្រិតសាកល្បង
  - ការរើសអើងនយោបាយ គួរតែត្រូវកាត់បន្ថយ និងដោះស្រាយ ដោយការជូនដំណឹង រំលឹកទៅមន្ត្រីដែលមានសមត្ថកិច្ចក្នុងកម្មវិធីវិនិយោគឃុំ

# អនុសាសន៍ចម្បងៗ (២)

- ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន គួរតែត្រូវធ្វើឡើងដើម្បីស្វែងរកសំឡេង និងយោបល់ពីប្រជាពលរដ្ឋនៅមូលដ្ឋាន
  - ដំណោះស្រាយ ត្រូវតែសាមញ្ញ និងអាចទៅរួច
  - ពលរដ្ឋគួរបានទទួលនូវការពន្យល់ថាហេតុអ្វីដែលពួកគេត្រូវចូលរួម
  - គំនិតផ្តួចផ្តើម គួរតែធ្វើឡើង សាកល្បង និងកែសម្រួលជាបន្តបន្ទាប់ ដោយផ្អែកលើយោបល់ពលរដ្ឋ
- ដំណោះស្រាយបច្ចេកវិទ្យាព័ត៌មាន ចំពោះការចូលរួមនៅមូលដ្ឋាន គួរតែចាប់ផ្តើមជាមួយក្រុមយុវជន និងបន្តទៅក្រុមផ្សេងទៀត
  - ផ្តល់វគ្គបណ្តុះបណ្តាលទៅលើជំនាញបច្ចេកវិទ្យាព័ត៌មានដែលពាក់ព័ន្ធ ដល់ក្រុមយុវជន ដើម្បីឲ្យពួកគេអាចចូលរួមការងារអភិវឌ្ឍន៍ និងអភិបាលកិច្ចមូលដ្ឋាន
  - រៀបចំឲ្យមាននូវមធ្យោបាយអនឡាញសម្រាប់យុវជនដែលចាប់អារម្មណ៍ចំពោះអភិបាលកិច្ចមូលដ្ឋាន

# អនុសាសន៍ចម្បងៗ(៣)

- លើកកម្ពស់យុវជនស្ម័គ្រចិត្ត ក្នុងការធ្វើការងារជាមួយឃុំហើយផ្តល់ជំនាញ ពាក់ព័ន្ធនឹង បច្ចេកវិទ្យាព័ត៌មាន
  - បង្កើតឲ្យមាននូវមធ្យោបាយផ្លូវការមួយដើម្បីជ្រើសរើសយុវជនទៅធ្វើការនៅរដ្ឋបាលឃុំ
  - ផ្តល់វគ្គបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាព័ត៌មានដល់យុវជនដែលធ្វើការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ភ្ជាប់ការរៀនសូត្រផ្នែកបច្ចេកវិទ្យាព័ត៌មាន ទៅនឹងកិច្ចការរដ្ឋបាលប្រចាំថ្ងៃ របស់រដ្ឋបាលឃុំ
- បើអាច បង្កើតយន្តការ និងភាពជាដៃគូជាប្រចាំរវាងក្រុមប្រឹក្សាឃុំ និងអង្គការមិនមែនរដ្ឋាភិបាលទៅលើរបៀបលើកកម្ពស់ការចូលរួមរបស់យុវជន និងដំណោះស្រាយផ្នែកបច្ចេកវិទ្យាព័ត៌មាននៅមូលដ្ឋាន